## II - រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៨

### អនុក្រឹត្យលេខ ២៧ អនក្រ.បក
### ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង ៦
### សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ

( Functional Cooperation )

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី ២០កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០១៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តិទៅនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (ICN)
- យោងតាមតំរូវការចាំបាច់នៃការងារ

Downloaded from http://www.khmerlaws.com

**សម្រេច**

**មាត្រា ១ :** គណៈកម្មាធិការជាតិទាំង៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ ជាភាសាអង់គ្លេស « Functional Cooperation » ក្នុងគោលដៅដើម្បីទាញយកផលប្រយោជន៍ ជាអតិបរិមាណក្នុងការធ្វើកិច្ចសហប្រតិបត្តិការជំនាញនេះ ពីបណ្តាប្រទេស អាស៊ាន និងប្រទេសជាដៃគូចរចា (Dialoque Partners ) ។

**មាត្រា ២ :** គណៈកម្មាធិការជាតិទាំង៦ មានឈ្មោះ និងសមាសភាពដូចតទៅ :

១-គណៈកម្មាធិការជាតិស្តីពីមុខងារសាធារណៈ (National Committee on Civil Service)

| | |
|---|---|
| -ប្រធានស្ថាប័ន ឬ តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| -តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |
| -តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |
| -តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| -តំណាងក្រសួងផែនការ | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

២-គណៈកម្មាធិការជាតិ ស្តីពីវប្បធម៌ និងព័ត៌មាន(National Cmmittee on Culture and Information)

| | |
|---|---|
| -ប្រធានស្ថាប័ន ឬតំណាងក្រសួងព័ត៌មាន | ប្រធាន |
| -ប្រធានស្ថាប័ន ឬតំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| -តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |
| -តំណាងក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| -តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

៣-គណៈកម្មាធិការជាតិស្តីពីបរិស្ថាន (National Committee on Environment)

| | |
|---|---|
| -ប្រធានស្ថាប័ន ឬតំណាងក្រសួងបរិស្ថាន | ប្រធាន |
| -តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |

Downloaded from http://www.khmerlaws.com

- តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក
- តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងសាធារណៈការនិងដឹកជញ្ជូន សមាជិក
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងកិច្ចការនារី សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (National Committee for Combating Drug)

- ប្រធានស្ថាប័ន ឬតំណាងក្រសួងយុត្តិធម៌ ប្រធាន
- តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អនុប្រធានប្រចាំការ
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងការពារជាតិ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន សមាជិក
- តំណាងធនាគារជាតិ សមាជិក

៥- គណៈកម្មាធិការជាតិស្តីពីការអភិវឌ្ឍន៍សង្គម(National Committee on Social Development )

- ប្រធាន ឬតំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ប្រធាន
- តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អនុប្រធានប្រចាំការ
- តំណាងក្រសួងអប់រំយុវជននិងកីឡា សមាជិក

Downloaded from http://www.khmerlaws.com

| | |
|---|---|
| -តំណាងក្រសួងសុខាភិបាល | សមាជិក |
| -តំណាងក្រសួងកិច្ចការនារី | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ | សមាជិក |
| -តំណាងគណៈកម្មាធិការជាតិប្រឆាំងជម្ងឺអេគដ៍ | សមាជិក |
| -តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| -តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| -តំណាងក្រសួងបរិស្ថាន | សមាជិក |
| -តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| -តំណាងក្រសួងផែនការ | សមាជិក |
| -តំណាងធនាគារជាតិ | សមាជិក |
| -តំណាងមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា | សមាជិក |

៦-គណៈកម្មាធិការជាតិស្តីពី វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(National Coomitte on Science and Technology)

| | |
|---|---|
| -ប្រធាន ឬតំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | ប្រធាន |
| -តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |
| -តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| -តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| -តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| -តំណាងក្រសួងពត៌មាន | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| -តំណាងក្រសួងបរិស្ថាន | សមាជិក |

Downloaded from http://www.khmerlaws.com

**មាត្រា ៣ :** គណៈកម្មាធិការជាតិនីមួយៗត្រូវមានភារកិច្ចដូចតទៅ :

-ប្រធានគណៈកម្មាធិការជាតិនីមួយៗ និងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា មានតួនាទីជាអ្នកសំរបសំរួល (Focal Point) លើកិច្ចសហប្រតិបត្តិការតាមជំនាញនីមួយៗរបស់ខ្លួនជាមួយលេខាធិការដ្ឋានជាតិអាស៊ានទាំងអស់(ASEAN National Secretariats) លេខាធិការដ្ឋានអាស៊ាន (ASEAN Secretariat) និង បណ្ដាប្រទេសជាដៃគូចរចារបស់អាស៊ាន (ASEAN Dialogue Partners) ។

-ប្រធានគណៈកម្មាធិការជាតិនីមួយៗចាំបាច់ត្រូវសំរបសំរួលនូវរាល់កិច្ចសហប្រតិបត្តិការជំនាញទាំងអស់ជាមួយលេខាធិការដ្ឋានអាស៊ានកម្ពុជា ដែលជាសេនាធិការរបស់ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (I.C.N) ។

-ពិនិត្យនិងសំរេចបញ្ជូនគណៈប្រតិភូសមស្របទៅចូលរួមប្រជុំ និងចូលរួមសកម្មភាពនានាតាមមុខជំនាញនីមួយៗ ។

-ក្រោយពេលត្រឡប់មកវិញ គណៈប្រតិភូចូលរួមត្រូវរាយការណ៍ជាលាយល័ក្ខអក្សរជូនគណៈកម្មាធិការជាតិនិងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជាពីលទ្ធផលនៃកិច្ចប្រជុំ។

**មាត្រា ៤ :** -សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិនីមួយៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

-ក្នុងករណីចាំបាច់ សមាជិកទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុងចូលរួមក្នុងអង្គប្រជុំតាមការអញ្ជើញរបស់អនុប្រធានប្រចាំការ ។

-ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការជាតិ ឬ អនុប្រធានប្រចាំការមានសិទ្ធិអញ្ជើញប្រធាន ឬ តំណាងស្ថាប័នក្រសួងពាក់ព័ន្ធចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ៥ :** -កិច្ចប្រជុំរបស់គណៈកម្មាធិការជាតិនីមួយៗ ត្រូវប្រព្រឹត្តទៅនៅក្នុងក្រសួង ឬស្ថាប័នរបស់ប្រធាន គណៈកម្មាធិការជាតិ ឬតាមការចាំបាច់នៅលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ។

-ប្រធានគណៈកម្មាធិការជាតិ
មានសិទ្ធិប្រើប្រាស់បន្ថែមអង្គភាពអាស៊ាននៅក្នុងក្រសួង ឬ ស្ថាប័ន របស់ខ្លួនជាលេខាធិការដ្ឋាននៃអង្គប្រជុំ ។

Downloaded from http://www.khmerlaws.com

**មាត្រា ៦ :** លេខាធិការដ្ឋាននៃអង្គប្រជុំត្រូវរាយការណ៍ជាលាយលក្ខអក្សរពីលទ្ធផលនៃកិច្ចប្រជុំជូនលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសមាជិកទាំងអស់ នៃអង្គប្រជុំ ។

**មាត្រា ៧ :** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា បណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និងត្រា ហត្ថលេខាត្រានិងត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ៥៧ អនក្រ.តត**

**ស្តីពីការជូនមេដាយសហមេត្រី**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

Downloaded from http://www.khmerlaws.com